# ទេវធីតាពីឋានតាវត្តិង្ស

កាលពីយូរយារកន្លងមកហើយ កាលដែលព្រះបាទកាសីសោយរាជ្យសម្បត្តិក្នុងសុរុន្ធនគរ ព្រះពោធិសត្វបានច្យុតចាកព្រហ្មលោកចាប់បដិសន្ធិក្នុងគភ៌របស់ព្រះរាជអគ្គមហេសីនៃព្រះបាទកាសី មានព្រះនាមថា ឧទយភ័ទ្រ ពេលដែលព្រះរាជកុមារចំរើនវ័យអាចយាងបាន ក៏មានព្រហ្មមួយអង្គច្យុតចាកព្រហ្មលោក មកចាប់កំណើតជាកុមារិកាក្នុងព្រះគភ៌របស់ព្រះមហេសីមួយអង្គទៀតរបស់ព្រះបាទកាសី មានព្រះនាមថា ឧទយភទ្រា ។

ព្រះរាជកុមារទ្រង់មានវ័យវឌ្ឍនាការចំរើនឡើង បានសិក្សាសិល្ប៍សាស្ត្រវិជ្ជាចប់សព្វគ្រប់ តែដោយទ្រង់ជាព្រហ្មចារី( អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ)ពីកំណើត ទ្រង់មិនដែលដឹងឬស្គាល់រឿងមេថុនធម្មឡើយ សូម្បីតែយល់សប្តិ ។

ព្រះរាជាទ្រង់មានព្រះរាជបំណងនឹងរៀបអភិសេកព្រះរាជឱរស ហើយទ្រង់ផ្ញើរាជសារ ទៅថា ពេលនេះជាពេលដែលកូននឹងត្រូវសោយសុខនៅក្នុងរាជសម្បត្តិ ពុកនឹងលើករាជសម្បត្តិទាំងអស់អោយកូន ។

ព្រះពោធិសត្វទ្រង់ក្រាបទូលបដិសេធរាជសម្បត្តិថា ចិត្តរបស់ទូលព្រះបង្គំមិនមានជាប់ជំពាក់នឹងរាជសម្បត្តិទេ ។

ពេលដែលទទួលព្រះរាជតម្រាស់តឿនញយ១ ព្រះពោធិសត្វក៏អោយជាងសាងរូបស្ត្រីដ៏ស្រស់ស្អាតពីមាសជម្ពូនុទ ( មាសដែលល្អវិសេសជាងគេលើលោក) ដ៏ចែងចាំងហើយទ្រង់ផ្ញើសារទៅថ្វាយបិតាថា បើទូលបង្គំបានជួបស្ត្រីមានរូបឆោម ដូចចម្លាក់មាសនេះ ទូលបង្គំនឹងទទួលរាជសម្បត្តិ ។

ព្រះរាជមាតាបិតាទ្រង់អោយអាមាត្យនាំយករូបមាសសុវណ្ណនោះដើរត្រាច់ស្វែងរកស្ត្រីដែលមានរូបឆោមស្រស់ស្អាតដូចចម្លាក់មាសសុវណ្ណនោះពាសពេញជម្ពូទ្វីប លុះរកស្វែងពុំបានស្រីដែលមានរូបស្អាតដូច្នោះ ក៏រៀបចំអភិសេកព្រះនាងឧទយភ័ទ្រអោយជាអគ្គមហេសីរបស់ព្រះរាជកុមារនោះ ទាំងដែលស្តេចទាំងពីរព្រះអង្គនោះមិនបានគិតប្រាថ្នាសោះ ហើយរូបឆោមរបស់ព្រះនាងទ្រង់ស្រស់ស្អាតលើសមាសសុវណ្ណសូន្យនោះទៅទៀត ។

ក្រោយមក ព្រះរាជបិតានិងព្រះរាជមាតាបានសោយទិវង្គតទៅ ព្រះពោធិសត្វក៏ទ្រង់ឡើងគ្រងរាជសម្បត្តិ ។ សូម្បីស្តេចទាំងពីរព្រះអង្គទ្រង់ប្រថាប់ក្នុងបន្ទប់តែមួយជាមួយគ្នាយ៉ាងណាក៏ដោយ

ក៏មិនបានទតព្រះនេត្ររកគ្នាដោយអំណាចរាគៈឡើយទ្រង់សន្យានឹងគ្នាថា យើងទាំងពីរនាក់ បើនរណាអស់ព្រះជន្មមុន អ្នកនោះត្រូវមកប្រាប់ថា ខ្ញុំទៅកើតក្នុងទីនោះៗ ។

រយៈពេលកន្លងទៅ ៧០០ ឆ្នាំ រាប់ចាប់តាំងពីថ្ងៃអភិសេកទៅ ព្រះពោធិសត្វក៏ទ្រង់ចូលទីវង្គតដោយពុំមាននរណានឹងឡើងស្នងរាជ្យបន្ត ព្រះនាងឧទយភទ្រាក៏ទ្រង់មើលការខុសត្រូវព្រះនគរជំនួសព្រះពោធិសត្វ ។

ចំណែកព្រះពោធិសត្វបានទៅកើតជាស្តេចសក្កទេវរាជនៅនាឋានតាវត្តិង្ស ព្រោះតែទ្រង់មានសក្តិខ្ពង់ខ្ពស់ ព្រះអង្គមិនអាចរលឹកបានអស់រយៈពេលមួយសប្តាហ៍ ពេលវេលាក៏កន្លងហួសទៅ៧០០ឆ្នាំដោយការរាប់ឆ្នាំរបស់មនុស្ស ។ ពេលព្រះអង្គទ្រង់រលឹកនឹកឃើញដល់ពាក្យសន្យា ទ្រង់ក៏មានព្រះតម្រិះថា យើងនឹងពិសោធព្រះរាជធីតាឧទយភទ្រាដោយទ្រព្យ ហើយសំដែងធម៌ដើម្បីដោះកិច្ចសន្យាដែលបានសន្យាទុក ។

មានសេចក្តីដំណាលថា សម័យនោះមនុស្សមានអាយុមួយម៉ឺនឆ្នាំ នៅយប់នោះព្រះរាជធីតាទ្រង់គង់ប្រថាប់ស្ងឹងស្ងាធីមិនកំរើក ទ្រង់រលឹកពីសីលរបស់ព្រះនាងតែមួយព្រះអង្គឯង ក្នុងបន្ទប់ជាន់ខ្ពស់បំផុតនៃមហាប្រាសាទ៧ជាន់ ដែលរាជបុរសបានបិទទ្វារការពារយ៉ាងរឹងមាំ ។

កាលនោះ សក្កទេវរាជទ្រង់កាន់ថាសមាសមួយដាក់ដុំមាសរហូតដល់ពេញ ហើយទៅប្រាកដព្រះកាយក្នុងបន្ទប់របស់ព្រះរាជធីតា ត្រាស់ថាៈ

នែ! ព្រះនាងដ៏មានរូបឆោមបវរល្អផូរផង់ ទ្រង់ព្រះភូសា (សំលៀកបំពាក់) ដ៏ស្រស់ស្អាតយាងកាន់ប្រាសាទគង់ប្រថាប់តែមួយព្រះអង្គឯង ទូលបង្គំសូមអង្វរព្រះនាង យើងទាំងពីរនាក់ គួរនៅរួមសុខជាមួយគ្នាអស់មួយរាត្រីនេះ ។

ធីតាៈ នគរនេះមានគូទឹកព័ទ្ធជុំវិញ មានកំពែងនិងខ្លោងទ្វារដ៏រឹងមាំ មានទាហានកាន់អាវុធការពារគ្រប់ច្រកល្ហក ដូច្នេះព្រះរាជវាំងនេះជាកន្លែងដែលគ្មាននរណាអាចចេញចូលបាន ម្តេចបានជាអ្នកអាចលួចចូល មកជួបខ្ញុំក្នុងវេលានេះបាន ហើយអ្នកមានគោលបំណងអ្វី?

សក្កៈ ទូលបង្គំជាទេវបុត្រ មកដល់ព្រះតំណាក់នេះដោយទេវានុភាព សូមយាងព្រះនាងមកសេពសុខជាមួយទូលបង្គំមក៏ ទូលបង្គំនឹងថ្វាយថាសមាសដែលពេញទៅដោយដុំមាសដល់ព្រះនាង ។

ធីតាៈ ក្រៅពីព្រះបាទឧទ័យ ខ្ញុំមិនប្រាថ្នាទេវតា យក្ស ឬមនុស្សដទៃឡើយ ម្នាលទេវបុត្រ

ដ៏មានអានុភាពច្រើន សូមអ្នកចេញអោយផុតទៅ ហើយកុំត្រឡប់មកទៀត ។

ស្តេចសក្កៈទ្រង់ស្តាប់ព្រះវាចានោះហើយ ក៏រលាយព្រះអង្គបាត់ទៅមួយរំពេច ។

រាត្រីបន្ទាប់មក ក្នុងវេលាដដែល ស្តេចសក្កៈទ្រង់បង្ហាញខ្លួនព្រមជាមួយនឹងថាសប្រាក់ដែលពេញទៅដោយដុំប្រាក់ ហើយត្រាស់ថាៈ

សេចក្តីរីករាយណាមួយដែលជាសេចក្តីសុខបំផុតរបស់អ្នកបរិភោគកាម សត្វទាំងឡាយប្រព្រឹត្តមិនគប្បីដោយហេតុនៃសេចក្តីរីករាយណាមួយ សូមព្រះនាងកុំអោយសេចក្តីរីករាយនោះរំលងផុតទៅ ទូលបង្គំមិនមែនមកដៃទទេទេ យប់មុននាំយកថាសមាសពេញដោយដុំមាស យប់នេះក៏នាំយកថាសប្រាក់ដែលពេញដោយដុំប្រាក់មក ទូលបង្គំសូមថ្វាយថាសដែលពេញដោយដុំប្រាក់នេះដល់ព្រះនាង ។

ព្រះរាជធីតាទ្រង់ព្រះតម្រិះថា ទេវបុត្រនេះ កាលបើសន្ទនាប្រាស្រ័យជាមួយ ច្បាស់ជានឹងមកញឹកញាប់ ពេលនេះនឹងឈប់និយាយជាមួយគេម្តង
គិតហើយទ្រង់គង់ស្ងៀមឥតតបតវាចាអ្វីទាំងអស់ ។

ស្តេចសក្កៈទ្រង់ជ្រាបហេតុដែលព្រះនាងមិនត្រាស់តបហើយក៏ទ្រង់រលាយខ្លួនបាត់ពីទីនោះ ។

យប់បន្ទាប់មកទៀត លុះដល់វេលាដដែល សក្កទេវរាជទ្រង់កាន់ថាសលោហៈដែលដាក់ពេញទៅដោយដុំលោហៈ ហើយត្រាស់ថាៈ

សូមព្រះនាងមេត្តាផ្គាប់ផ្គុនទូលបង្គំ ដោយសេចក្តីរីករាយក្នុងកាមចុះ ទូលបង្គំនឹងថ្វាយថាសលោហៈដែលដាក់ពេញដោយដុំលោហៈដល់ព្រះនាង ។

ធីតាៈ អ្នកអីក៏ល្ងង់ម្ល៉េះ! កាលបុរសមានបំណងនឹងទាក់ទាញចិត្តស្ត្រីដោយទ្រព្យ រមែងនាំយកនូវទ្រព្យដែលជាទីពេញចិត្តរបស់នាងមកអោយ តែផ្ទុយទៅវិញ អ្នកបែរជានាំយកទ្រព្យដែលថយតំលៃជាលំដាប់មកអោយ ។

សក្កៈ ហៃ ព្រះនាងដ៏មានព្រះឆោមលោមពណ៌ស្រស់ត្រកាល អាយុនិងសម្រស់របស់ពួកមនុស្សក្នុងមនុស្សលោករមែងទ្រុឌទ្រោមទៅជាលំដាប់ ព្រោះហេតុនោះ ទ្រព្យសំរាប់ព្រះនាងក៏ចាំបាច់ត្រូវតែថយចុះ ព្រោះថ្ងៃនេះព្រះនាងកាន់តែចាស់ជាងថ្ងៃមុន ។

ម្នាលព្រះរាជធីតា យប់ថ្ងៃចេះតែកន្លងទៅឥតឈប់ អាយុនិងវណ្ណៈរបស់មនុស្សក៏ទ្រុឌទ្រោមទៅ ពេលដែលទូលបង្គំកំពុងសំលឹងពិនិត្យមើលព្រះនាងយ៉ាងនេះ ព្រះឆវីវណ្ណរបស់ព្រះនាងកាន់តែ

អាប់ស្រពោនទៅជាលំដាប់ ព្រោះហេតុនោះ ព្រះនាងគប្បីប្រព្រឹត្តព្រហ្មចរិយធម៌ចាប់តាំងពីថ្ងៃនេះតែម្តងទៅ ព្រះនាងនឹងមានព្រះឆវីវណ្ណកាន់តែស្រស់ប៉ប្រិមរឹតតែខ្លាំងឡើង ។

ធីតាៈ ទេវតាទាំងឡាយមិនចាស់ដូចមនុស្សទេឬ រាងកាយរបស់ទេវតាមានសរសៃដែរឬទេ រាងកាយរបស់ទេវតានោះមានសភាពយ៉ាងណា ?

សក្កៈ ពួកទេវតាមិនចាស់ដូចមនុស្សទេ រាងកាយរបស់ទេវតាមិនមានសរសៃទេ ឆវីវណ្ណដ៏ជាទិព្វរបស់ទេវតារឹតតែផូរផង់ឡើងជារៀងរាល់ថ្ងៃ ហើយភោគសម្បត្តក៏រឹតតែសម្បូរហូរហៀរឡើងជារៀងរាល់ថ្ងៃ។

ធីតាៈ បុគ្គលតាំងនៅក្នុងគុណធម៌អ្វីទើបមិនខ្លាចបរលោក?

សក្កៈ អ្នកណាតាំងវាចាត្រូវ តាំងចិត្តត្រូវ មិនធ្វើបាបដោយកាយ នៅគ្រប់គ្រងផ្ទះដែលមានបាយទឹកបរិបបូរណ៍ ជាអ្នកមានសទ្ធា ទន់ភ្លន់ ចេះធ្វើទានដល់អ្នកកំសត់ទុគតិ ដឹងបំណង ចូលចិត្តសង្គ្រោះ មានវាចាគួរសេពគប់ជាមិត្ត អ្នកនោះមិនគប្បីខ្លាចបរលោកឡើយ ។

ធីតាៈ អ្នកជានរណាទៅ បានជាហ៊ានមកប្រៀនប្រដៅនាងខ្ញុំ?

សក្កៈ ជាតិមុនខ្ញុំជាព្រះបាទឧទ័យ ជាតិនេះជាសក្កទេវរាជ មកកាន់ទីនេះដើម្បីដោះពាក្យសន្យាឥឡូវនេះខ្ញុំសូមលាទៅវិញព្រោះបានបំពេញតាមពាក្យសន្យារួចហើយ ។

ធីតាៈ បើព្រះអង្គជាព្រះបាទឧទ័យ សូមព្រះអង្គមេត្តាប្រាសប្រៀនប្រដៅខ្ញុំម្ចាស់នូវវិធីដែលយើងអាចបានជួបគ្នាជាថ្មីផង ។

សក្កៈ វ័យកន្លងទៅឆាប់រហ័សណាស់ ជីវិតនិងរាងកាយមានតែចាស់ជរាទ្រុឌទ្រោមទៅជារៀងរាល់ថ្ងៃ មិនទៀង មិនស្ថិតស្ថេរ សត្វទាំងឡាយសុទ្ធតែបែរមុខឆ្ពោះទៅកាន់ការបែកធ្លាយ ហេតុនេះចូរនាងកុំប្រមាទ ចូរខំប្រព្រឹត្តធម៌ចុះ ។

បុគ្គលដែលធ្លាក់ក្នុងអំណាចតណ្ហា ទោះជាគ្រប់គ្រងសម្បត្តិមហាសាលតែម្នាក់ឯងក៏នៅមិនឆ្អែតមិនជិនណាយ តែពេលដែលសេចក្តីស្លាប់មកដល់ហើយ ក៏ចាកចោលអ្វីៗគ្រប់យ៉ាងទៅទាំងអាល័យហេតុនេះ ចូរនាងកុំប្រមាទ ចូរខំប្រព្រឹត្តធម៌ចុះ ។

មាតា បិតា បងប្រុស ប្អូនប្រុស បងស្រីប្អូនស្រី ព្រមទាំងទ្រព្យសម្បត្តិ សូម្បីគេទាំងអស់នោះម្នាក់ៗក៏គង់នឹងចាកចោលគ្នានិងគ្នាទៅ សុគតិនិងទុគ្គតិក្នុងសង្សារវដ្តនេះ ជាកន្លែងសំរាប់ស្នាក់

អាស្រ័យបណ្តោះអាសន្ន ការមកពីកន្លែងផ្សេងៗហើយជួបគ្នា រស់នៅជាមួយគ្នារបស់សត្វទាំងឡាយ ក៏គ្រាន់តែមួយរយៈកាលដ៏ខ្លីប៉ុណ្ណោះ ហេតុនេះ ចូរនាងកុំប្រមាទ ចូរខំប្រព្រឹត្តធម៌ចុះ ។

ព្រះពោធិសត្វប្រទានឱវាទរួចហើយក៏យាងត្រឡប់ទៅទេវលោកវិញ ។

ព្រះរាជធីតាទ្រង់ជ្រះថ្លាក្នុងធម្មកថា លុះព្រឹកឡើងក៏ទ្រង់ប្រគល់រាជសម្បត្តិអោយពួកអាមាត្យ ទ្រង់សាងព្រះផ្នួសជាតាបសិនីក្នុងព្រះរាជឧទ្យានដ៏សុខសប្បាយក្នុងព្រះនគរនោះឯង ទ្រង់ប្រព្រឹត្តធម៌ ទីបំផុតនៃព្រះជន្មាយុ ក៏បានកើតជាបាទបរិចារិកា(ភរិយា)របស់ព្រះពោធិសត្វក្នុងឋានតាវត្តិង្ស ។

*(ឧទយជាតកនិងអដ្ឋកថា)*

រឿងនេះមានខ្លឹមសារដូចតទៅ:

១-អ្នកដែលច្យុតពីព្រហ្មលោកមកកើតជាមនុស្សរមែងមានរាគៈស្តើង ហេតុនេះព្រះពោធិសត្វ និងព្រះរាជធីតាអាចរស់នៅជាមួយគ្នាដោយប្រព្រឹត្តព្រហ្មចរិយធម៌ មិនប្រព្រឹត្តលោកិយវិស័យ ។

២-ក្នុងពួកមនុស្ស ការទ្រុឌទ្រោមទៅនៃរូបឆោមជាសាក្សីថាកើតមកយូរហើយ ក្នុងពពួកទេវតារូបសម្បត្តិរឹតតែល្អ បរិវារសម្បត្តិរឹតតែច្រើនឡើង ជាសាក្សីថាកើតមកយូរហើយ ។

៣-មនុស្សក្នុងសម័យកាលនីមួយៗមានអាយុក្ស័យ (ការអស់ទៅនៃអាយុ) ខុសគ្នា នៅក្នុងឧទយជាតក មនុស្សមានអាយុ១ម៉ឺនឆ្នាំ ក្នុងសម័យបច្ចុប្បន្នមនុស្សមានអាយុតិច មិនដល់មួយរយឆ្នាំ ក៏ស្លាប់ទៅហើយ ។

សំរាប់មនុស្សដែលនៅមានជីវិតនៅឡើយ យប់ថ្ងៃកន្លងទៅយ៉ាងឆាប់រហ័ស ពេលវេលានៃជីវិតក៏កាន់តែសល់តិចទៅៗគ្រប់ខណៈ កាលបើជីវិតនិងរាងកាយមានតែការចាស់ជរាទៅ ចូលទៅក្បែរមាត់ជ្រោះមរណៈគ្រប់ខណៈយ៉ាងនេះ គ្រប់គ្នាគួររលឹកជានិច្ចថា:

**យប់និងថ្ងៃចេះតែកន្លងផុតទៅ ពេលនេះ យើងកំពុងធ្វើអ្វី?**

ប្រែនិងរៀបរៀងដោយ

ភិក្ខុ វណ្ណគុត្តោ ស្វាត សាលឿម